# អភិធម្មត្ថសង្គហបាលី-ប្រែ

# ចិត្តបរមត្ថ

# បរិច្ឆេទទី ១

ប្រែដោយភិក្ខុ នួន សារ៉េត

ព.ស២៥៦០, គ.ស ២០១៦

# សេចក្ដីផ្ដើម

សៀវភៅនេះ ខ្ញុំព្រះករុណា អាត្មាភាព ភិក្ខុ សារត្ថធម្មោ នួន សារ៉េត បានរៀបរៀងឡើង ដើម្បីជាប្រយោជន៍ដល់ពុទ្ធបរិស័ទទូទៅ បានការសិក្សាស្រាវជ្រាវ និងបដិបត្តិក្នុងព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធ ដើម្បីជាប្រយោជន៍ ដល់សង្គមជាតិ សាសនា របស់ខ្មែរយើង នឹងជួយជាចំណេះដឹង ដល់កុលបុត្រ កុលធីតា ប្អូនៗ បងៗ ជានិស្សិត ក្នុងសៀវភៅនេះផងដែរ ។

ពិតណាស់ សង្គមមួយ ដែលមានមនុស្សចេះដឹងច្រើន យល់ដឹងច្រើន នឹងឈានទៅរកការអភិវឌ្ឍបានរីកចម្រើន ភាពសម្បូរសប្បាយ លូតលាស់ ជឿនលឿន ប្រកបដោយសុខចម្រើនក្នុងសង្គមនោះពុំខាន ។ ហេតុនេះហើយ ខ្ញុំព្រះករុណា អាត្មាភាព នឹងសង្ឃឹមថា សៀវភៅនេះនឹងបានជាយោជន៍ដល់ជនច្រើន ។

សេចក្ដីរៀបរាប់មកខាងលើនេះ សូមជូនពរ ឲ្យពុទ្ធបរិស័ទទាំងអស់ និង ប្អូនៗ បងៗ សិក្សា បដិបត្តិ ឲ្យបានជាប្រយោជន៍ ជាចំណេះដឹង ជាមេរៀន ជាមេគំនិត សម្រាប់ដំណើរជីវិតនេះ ប្រកបតែសេចក្ដីសុខ សេចក្ដីចម្រើន និង រួចចាកទុក្ខទាំងពួង កុំបីអាក់ខានឡើយ ។

សូមថ្វាយព្រះរាជកុសលនេះ ដល់ព្រះមហាក្សត្រាក្សត្រីខ្មែរគ្រប់ជំនាន់ និងថ្វាយព្រះរាជកុសលដល់ព្រះសង្ឃរាជទាំងទាំងពីរគណៈគ្រប់ជំនាន់ និងមន្ត្រីសង្ឃគ្រប់រូប ព្រមទាំងបុព្វបុរសវីរៈជនខ្មែរគ្រប់រូប ពុទ្ធបរិស័ទទាំងអស់ សូមអនុមោទនានូវធម្មទាន ដែលខ្ញុំព្រះករុណា អាត្មាភាព បានបំពេញនេះ ហើយសូមឲ្យតែបានសេចក្ដីសុខ សេចក្ដីចម្រើន និងរួចចាកទុក្ខទាំងពួងកុំបីអាក់ខានឡើយ ។

វត្តស្រះមុជ្ឈលិន្ទ ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២៣

ភិក្ខុសារត្ថធម្មោ នួន សារ៉េត

# មាតិកា ទំព័រ


| | |
|---|---|
| ១-គាថាប្រារព្ធខាងដើម | ៣ |
| ២-ភូមិភេទចិត្ត ៤ ប្រភេទ | ៣ |
| ៣-អកុសលចិត្ត ១២ ដួង (លោភមូលចិត្ត ៨ ដួង) | ៤ |
| ៤-ទោសមូលចិត្ត ២ ដួង | ៤ |
| ៥-មោហមូលចិត្ត ២ ដួង | ៥ |
| ៦-អហេតុកចិត្ត ១៨ ដួង (អកុសលវិបាកចិត្ត ៧ ដួង) | ៥ |
| ៧-អហេតុកកុសលវិបាកចិត្ត ៨ ដួង | ៦ |
| ៨-អហេតុកកិរិយាចិត្ត ៣ ដួង | ៧ |
| ៩-កាមាវចរសោភណចិត្ត ២៤ ដួង (មហាកុសលចិត្ត ៨ ដួង) | ៨ |
| ១០-មហាវិបាកចិត្ត ៨ ដួង | ៩ |
| ១១-មហាកិរិយាចិត្ត ៨ ដួង | ៩ |
| ១២-រូបាវចរចិត្ត ១៥ ដួង (កុសលចិត្ត ៥ ដួង) | ១០ |
| ១៣- លោកុត្តរចិត្ត ៨ ឬ ៤០ | ១៤ |

# អភិធម្មត្ថសង្គហៈ

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។**

[១]សម្មាសម្ពុទ្ធ'មតុលំ សសទ្ធម្មគណុត្តមំ;

អភិវាទិយ ភាសិស្សំ, អភិធម្មត្ថសង្គហំ ។

ខ្ញុំព្រះករុណា (ឈ្មោះព្រះអនុរុទ្ធាចារ្យ) សូមនមស្ការ ចំពោះព្រះសម្មាសម្ពុទ្ធ ជាម្ចាស់ទ្រង់ត្រាស់ដឹងដោយប្រពៃចំពោះព្រះអង្គឯង មិនមាននរណាមួយស្មើនឹងព្រះអង្គ -ឡើយ ព្រមទាំងសូមនមស្ការ ចំពោះព្រះធម៌ និងព្រះសង្ឃ ដ៏ប្រសើរខ្ពង់ខ្ពស់, ខ្ញុំព្រះ- ករុណា នឹងពោលនូវគម្ពីរអភិធម្មត្ថសង្គហៈ តទៅ ។

## បរមត្ថធម៌ ៤ ប្រភេទ

[២] តត្ថ វុត្តា'ភិធម្មត្ថា, ចតុធា បរមត្ថតោ;

ចិត្តំ ចេតសិកំ រូបំ, និព្វានមីតិ សព្វថា ។

អត្ថនៃព្រះអភិធម្ម ដែលលោកពោលក្នុងគម្ពីរអភិធម្មត្ថសង្គហៈនោះ ដោយបរមត្ថ ធម៌មាន ៤ យ៉ាងគឺៈ ចិត្ត ១, ចេតសិក ១, រូប ១, និព្វាន ១, ដោយប្រការ ទាំងពួង ។

## ១. ចិត្តបរិច្ឆេទ

## ភូមិភេទចិត្ត ៤ ប្រភេទ

តត្ថ ចិត្តំ តាវ, ចតុព្វិធំ ហោតិ កាមាវចរំ រូបាវចរំ អរូបាវចរំ លោកុត្តរញ្ចេតិ ។

បណ្ដាអត្ថនៃព្រះអភិធម្ម ៤ ប្រការនោះ លំដាប់ជាដំបូង ចិត្តមាន ៤ ប្រការ គឺ កាមាវចរចិត្ត ១, រូបាវចរចិត្ត ១, អរូបាវចរចិត្ត ១, លោកុត្តរចិត្ត ១ ។

## អកុសលចិត្ត ១២ ដួង

[៤]តត្ថ កតមំ កាមាវចរំ បណ្ដាកាមាវចរចិត្តនោះ តើដូចម្ដេច ?

## អកុសលចិត្ត ១២ ដួង

## លោភមូលចិត្ត ៨ ដួង

សោមនស្សសហគតំ ទិដ្ឋិគតសម្បយុត្តំ អសង្ខារិកមេកំ, សសង្ខារិកមេកំ, សោមនស្សសហគតំ ទិដ្ឋិគតវិប្បយុត្តំ អសង្ខារិកមេកំ, សសង្ខារិកមេកំ; ឧបេក្ខាសហគតំ ទិដ្ឋិគតសម្បយុត្តំ អសង្ខារិកមេកំ, សសង្ខារិកមេកំ, ឧបេក្ខាសហគតំ ទិដ្ឋិគតវិប្បយុត្តំ អសង្ខារិកមេកំ, សសង្ខារិកមេកន្តិ ឥមានិ អដ្ឋបិ លោភសហគតចិត្តានិ នាម ។

១.លោភមូលចិត្ត កើតរួមជាមួយនឹង សោមនស្សវេទនា ប្រកបដោយទិដ្ឋិ មិនមានអ្នកដទៃបបួលដឹកនាំ ។

២. លោភមូលចិត្ត កើតរួមជាមួយនឹង សោមនស្សវេទនា ប្រកបដោយទិដ្ឋិ មានអ្នកដទៃបបួលដឹកនាំ ។

៣. លោភមូលចិត្ត កើតរួមជាមួយនឹង សោមនស្សវេទនា ប្រាសចាកទិដ្ឋិ មិនមានអ្នកដទៃបបួលដឹកនាំ ។

៤. លោភមូលចិត្ត កើតរួមជាមួយនឹង សោមនស្សវេទនា ប្រាសចាកទិដ្ឋិ មានអ្នកដទៃបបួលដឹកនាំ ។

៥. លោភមូលចិត្ត កើតរួមជាមួយនឹង ឧបេក្ខាវេទនា ប្រកបដោយទិដ្ឋិ មិនមានអ្នកដទៃបបួលដឹកនាំ ។

៦. លោភមូលចិត្ត កើតរួមជាមួយនឹង ឧបេក្ខាវេទនា ប្រកបដោយទិដ្ឋិ មានអ្នកដទៃបបួលដឹកនាំ ។

៧. លោភមូលចិត្ត កើតរួមជាមួយនឹង ឧបេក្ខាវេទនា ប្រាសចាកទិដ្ឋិ មិនមានអ្នកដទៃបបួលដឹកនាំ ។

៨. លោភមូលចិត្ត កើតរួមជាមួយនឹង ឧបេក្ខាវេទនា ប្រាសចាកទិដ្ឋិ មានអ្នកដទៃបបួលដឹកនាំ ។

ចិត្តទាំង ៨ ដួងនេះ ឈ្មោះថា លោភសហគតចិត្ត (ចិត្តដែលកើតរួមជាមួយនឹងលោភ) ។

## ទោសមូលចិត្ត ២ ដួង

[៤]ទោមនស្សសហគតំ បដិឃសម្បយុត្តំ អសង្ខារិកមេកំ, សសង្ខារិកមេកន្តិ ឥមានិ ទ្វេបិ បដិឃសម្បយុត្តចិត្តានិ នាម ។

១. ទោសមូលចិត្ត កើតរួមជាមួយនឹង ទោមនស្សវេទនា ប្រកបដោយសេចក្តីថ្នាំងថ្នាក់ចិត្ត មិនមានអ្នកដទៃបបួលដឹកនាំ ។

២. ទោសមូលចិត្ត កើតរួមជាមួយនឹង ទោមនស្សវេទនា ប្រកបដោយសេចក្តីថ្នាំងថ្នាក់ចិត្ត មានអ្នកដទៃបបួលដឹកនាំ ។

ចិត្តទាំង ២ ដួងនេះ ឈ្មោះថា បដិឃសម្បយុត្តចិត្ត (ចិត្តប្រកបដោយសេចក្តីថ្នាំងថ្នាក់) ។

## មោហមូលចិត្ត ២ ដួង

[៦]ឧបេក្ខាសហគតំ វិចិកិច្ឆាសម្បយុត្តមេកំ, ឧបេក្ខាសហគតំ ឧទ្ធច្ចសម្បយុត្តសម្បយុត្តមេកន្តិ ឥមានិ ទ្វេបិ មោមូហចិត្តានិ នាម ។

១.មោហមូលចិត្ត កើតរួមជាមួយនឹង ឧបេក្ខាវេទនា ប្រកបដោយវិចិកិច្ឆា ។

២.មោហមូលចិត្ត កើតរួមជាមួយនឹង ឧបេក្ខាវេទនា ប្រកបដោយឧទ្ធច្ចៈ ។

ចិត្តទាំង ២ដួងនេះ ឈ្មោះថា មោហមូលចិត្ត (ចិត្តវង្វេងវង្វាន់) ។

## និគមន៍

[៧]ឥច្ចេវំ សព្វថាបិ ទ្វាទសាកុសលចិត្តានិ សមត្តានិ ។

ចប់អកុសលចិត្ត ១២ ដួង ដោយប្រការទាំងពួង ដូច្នេះឯង ។

## សង្គហគាថា

[៨]អដ្ឋធា លោភមូលានិ, ទោសមូលានិ ច ទ្វិធា;

មោហមូលានិ ច ទ្វេតិ ទ្វាទសាកុសលា សិយុំ។

អកុសលចិត្ត មាន ១២ ដួង គឺ លោភមូលចិត្ត ៨ ដួង, ទោសមូលចិត្ត ២ ដួង, មោហមូលចិត្ត ២ ដួង ។

## អហេតុកចិត្ត ១៨ ដួង

# អកុសលវិបាកចិត្ត ៧ ដួង

[៩]ឧបេក្ខាសហគតំ ចក្ខុវិញ្ញាណំ, តថា សោតវិញ្ញាណំ, ឃានវិញ្ញាណំ, ជិវ្ហាវិញ្ញាណំ, ទុក្ខសហគតំ កាយវិញ្ញាណំ, ឧបេក្ខាសហគតំ សម្បដិច្ឆន្នចិត្តំ, ឧបេក្ខាសហគតំ សន្តីរណចិត្តញ្ចេតិ

ឥមានិ សត្តបិ អកុសលវិបាកចិត្តានិ ជាម ។

១.អហេតុកអកុសលវិបាកចិត្ត ដែលអាស្រ័យ ចក្ខុបសាទ កើតរួមជាមួយនឹង ឧបេក្ខាវេទនា ។

២.ដូចគ្នានេះដែរ អហេតុកអកុសលវិបាកចិត្ត ដែលអាស្រ័យ សោតបសាទ កើតរួមជាមួយនឹង ឧបេក្ខាវេទនា ។

៣.អហេតុកអកុសលវិបាកចិត្ត ដែលអាស្រ័យ ឃានបសាទ កើតរួមជាមួយនឹង ឧបេក្ខាវេទនា ។

៤.អហេតុកអកុសលវិបាកចិត្ត ដែលអាស្រ័យ ជិវ្ហាបសាទ កើតរួមជាមួយនឹង ឧបេក្ខាវេទនា ។

៥. អហេតុកអកុសលវិបាកចិត្ត ដែលអាស្រ័យ កាយបសាទ កើតរួមជាមួយនឹង ទុក្ខវេទនា ។

៦.សម្បដិច្ឆន្នចិត្ត ដែលកើតរួមជាមួយនឹង ឧបេក្ខាវេទនា ។

៧.សន្តីរណចិត្ត ដែលកើតរួមជាមួយនឹង ឧបេក្ខាវេទនា ។

ចិត្តទាំង ៧ ដួងនេះ ឈ្មោះថា អកុសលវិបាកចិត្ត ។

# អហេតុកកុសលវិបាកចិត្ត ៨ ដួង

[១០]ឧបេក្ខាសហគតំ កុសលវិបាកំ ចក្ខុវិញ្ញាណំ, តថា សោតវិញ្ញាណំ, ឃានវិញ្ញាណំ, ជិវ្ហាវិញ្ញាណំ, សុខសហគតំ កាយវិញ្ញាណំ, ឧបេក្ខាសហគតំ សម្បដិច្ឆន្នចិត្តំ, សោមនស្សសហគតំ សន្តីរណចិត្តញ្ចេតិ ឥមានិ អដ្ឋបិ កុសលវិបាកាហេតុកចិត្តានិ ណាម ។

១.អហេតុកកុសលវិបាកចិត្ត ដែលអាស្រ័យចក្ខុបសាទ កើតរួមជាមួយនឹង ឧបេក្ខាវេទនា ដែលជាផលរបស់កុសលកម្ម ។

២.ដូចគ្នានេះដែរ អហេតុកកុសលវិបាកចិត្ត ដែលអាស្រ័យ សោតបសាទ កើតរួមជាមួយនឹង ឧបេក្ខាវេទនា ដែលជាផលរបស់កុសលកម្ម ។

៣.អហេតុកកុសលវិបាកចិត្ត ដែលអាស្រ័យ ឃានបសាទ កើតរួមជាមួយនឹង ឧបេក្ខាវេទនា ដែលជាផលរបស់កុសលកម្ម ។

៤.អហេតុកកុសលវិបាកចិត្ត ដែលអាស្រ័យ ជិវ្ហាបសាទ កើតរួមជាមួយនឹង ឧបេក្ខាវេទនា ដែលជាផលរបស់កុសលកម្ម ។

៥.អហេតុកកុសលវិបាកចិត្ត ដែលអាស្រ័យ កាយបសាទ កើតរួមជាមួយនឹង សុខវេទនា ។

៦.សម្បដិច្ឆន្នចិត្ត ដែលកើតរួមជាមួយនឹង ឧបេក្ខាវេទនា ។

៧.សន្តីរណចិត្ត ដែលកើតរួមជាមួយនឹង សោមនស្សវេទនា ។

៨.សន្តីរណចិត្ត ដែលកើតរួមជាមួយនឹង ឧបេក្ខាវេទនា ។

ចិត្តទាំង ៨ ដួងនេះ ឈ្មោះថា អហេតុកកុសលវិបាកចិត្ត ។

## អហេតុកកិរិយាចិត្ត ៣ ដួង

[១១]ឧបេក្ខាសហគតំ បញ្ចទ្វារាវជ្ជនចិត្តំ, តថា មនោទ្វារាវជ្ជនចិត្តំ, សោមនស្សសហគតំ ហសិតុប្បាទចិត្តញ្ចេតិ ឥមានិ តីណិបិ អហេតុកកិរិយចិត្តានិ នាម ។

១.អហេតុកកិរិយាចិត្ត ដែលត្រិះរិះអារម្មណ៍ តាមផ្លូវ បញ្ចទ្វារ កើតរួមជាមួយ នឹង ឧបេក្ខាវេទនា ។

២.ដូចគ្នានេះដែរ អហេតុកកិរិយាចិត្ត ដែលត្រិះរិះអារម្មណ៍ តាមផ្លូវ មនោទ្វារ កើតរួមជាមួយនឹង ឧបេក្ខាវេទនា ។

៣.អហេតុកកិរិយាចិត្ត ដែលញ៉ាំងការញញឹមឲ្យកើត រួមជាមួយនឹង សោមន- ស្សវេទនា ។

ចិត្តទាំង ៣ ដួងនេះ ឈ្មោះថា អហេតុកកិរិយាចិត្ត ។

[១២]ឥច្ចេវំ សព្វថាបិ អដ្ឋារសាហេតុកចិត្តានិ សមត្តានិ ។

ចប់អហេតុកចិត្ត ១៨ ដួង ដោយប្រការទាំងពួង ដូច្នេះឯង ។

## សង្គហគាថា

[១៣]សត្តាកុសលបាកានិ, បុញ្ញបាកានិ អដ្ឋធា;
ក្រិយចិត្តានិ តីណីតិ, អដ្ឋារស អហេតុកា ។

អហេតុកចិត្ត មាន ១៨ដួង គឺ អកុសលវិបាកចិត្ត ៧ដួង, អហេតុកកុសល-វិបាកចិត្ត ៨ដួង, និង អហេតុកកិរិយាចិត្ត ៣ ដួង ។

## សោភណចិត្ត ៥៩ ឬ ៩១

[១៤]បាបាហេតុកមុត្តានិ, សោភណានីតិ វុច្ចរេ;

ឯកូនសដ្ឋិ ចិត្តានិ, អថេកនវុតីបិ វា ។

ចិត្ត ៥៩ ដួង ឬ ចិត្ត ៩១ ដួងខ្លះ ក្រៅពីអកុសលចិត្ត ១២ ដួង និង អហេតុកចិត្ត ១៨ ដួង តទៅនេះ ហៅថា សោភណចិត្ត ។

## កាមាវចរសោភណចិត្ត ២៤ ដួង

## មហាកុសលចិត្ត ៨ ដួង

[១៥]សោមនស្សសហគតំ ញាណសម្បយុត្តំ អសង្ខារិកមេកំ, សសង្ខារិកមេកំ, សោមនស្សសហគតំ ញាណវិប្បយុត្តំ អសង្ខារិកមេកំ, សសង្ខារិកមេកំ, ឧបេក្ខាសហគតំ ញាណសម្បយុត្តំ អសង្ខារិកមេកំ, សសង្ខារិកមេកំ, ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ អសង្ខារិកមេកំ សសង្ខារិកមេកន្តិ ឥមានិ អដ្ឋបិ កាមាវចរកុសលចិត្តានិ នាម ។

១.មហាកុសលចិត្ត កើតរួមរួមជាមួយនឹង សោមនស្សវេទនា ប្រកបដោយ បញ្ញា មិនមានអ្នកដទៃបបួលដឹកនាំ ។

២.មហាកុសលចិត្ត កើតរួមជាមួយនឹង សោមនស្សវេទនា ប្រកបដោយបញ្ញា មានអ្នកដទៃបបួលដឹកនាំ ។

៣.មហាកុសលចិត្ត កើតរួមជាមួយនឹង សោមនស្សវេទនា ប្រាសចាកបញ្ញា មិនមានអ្នកដទៃបបួលដឹកនាំ ។

៤.មហាកុសលចិត្ត កើតរួមជាមួយនឹង សោមនស្សវេទនា ប្រាសចាកបញ្ញា មានអ្នកដទៃបបួលដឹកនាំ ។

៥.មហាកុសលចិត្ត កើតរួមជាមួយនឹង ឧបេក្ខាវេទនា ប្រកបដោយបញ្ញា មិនមានអ្នកដទៃបបួលដឹកនាំ ។

៦.មហាកុសលចិត្ត កើតរួមជាមួយនឹង ឧបេក្ខាវេទនា ប្រកបដោយបញ្ញា មានអ្នកដទៃបបួលដឹកនាំ ។

៧.មហាកុសលចិត្ត កើតរួមជាមួយនឹង ឧបេក្ខាវេទនា ប្រាសចាកបញ្ញា មិនមានអ្នកដទៃបបួលដឹកនាំ ។

៨.មហាកុសលចិត្ត កើតរួមជាមួយនឹង ឧបេក្ខាវេទនា ប្រាសចាកបញ្ញា មានអ្នកដទៃបបួលដឹកនាំ ។

ចិត្តទាំង ៨ដួងនេះ ឈ្មោះថា កាមាវចរកុសលចិត្ត ។

## មហាវិបាកចិត្ត ៨ ដួង

[១៦]សោមនស្សសហគតំ ញាណសម្បយុត្តំ អសង្ខារិកមេកំ, សសង្ខារិកមេកំ, សោមនស្ស សហគតំ ញាណវិប្បយុត្តំ អសង្ខារិកមេកំ, សសង្ខារិកមេកំ, ឧបេក្ខាសហគតំ ញាណសម្បយុត្តំ អសង្ខារិកមេកំ,

សសង្ខារិកមេកំ, ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ អសង្ខារិកមេកំ, សសង្ខារិកមេកន្តិ ឥមានិ អដ្ឋបិ សហេតុកកាមាវចរវិបាកចិត្តានិ ជាម ។

១.មហាវិបាកចិត្ត កើតរួមជាមួយនឹង សោមនស្សវេទនា ប្រកបដោយបញ្ញា មិនមានអ្នកដទៃបបួលដឹកនាំ ។

២.មហាវិបាកចិត្ត កើតរួមជាមួយនឹង សោមនស្សវេទនា ប្រកបដោយបញ្ញា មានអ្នកដទៃបបួលដឹកនាំ ។

៣.មហាវិបាកចិត្ត កើតរួមជាមួយនឹង សោមនស្សវេទនា ប្រាសចាកបញ្ញា មិនមានអ្នកដទៃបបួលដឹកនាំ ។

៤.មហាវិបាកចិត្ត កើតរួមជាមួយនឹង សោមនស្សវេទនា ប្រាសចាកបញ្ញា មានអ្នកដទៃបបួលដឹកនាំ ។

៥.មហាវិបាកចិត្ត កើតរួមជាមួយនឹង ឧបេក្ខាវេទនា ប្រកបដោយបញ្ញា មិនមានអ្នកដទៃបបួល-ដឹកនាំ ។

៦.មហាវិបាកចិត្ត កើតរួមជាមួយនឹង ឧបេក្ខាវេទនា ប្រកបដោយបញ្ញា មានអ្នកដទៃបបួលដឹកនាំ ។

៧.មហាវិបាកចិត្ត កើតរួមជាមួយនឹង ឧបេក្ខាវេទនា ប្រាសចាកបញ្ញា មិនមានអ្នកដទៃបបួលដឹកនាំ ។

៨.មហាវិបាកចិត្ត កើតរួមជាមួយនឹង ឧបេក្ខាវេទនា ប្រាសចាកបញ្ញា មានអ្នកដទៃបបួលដឹកនាំ ។

ចិត្តទាំង ៨ដួងនេះ ឈ្មោះថា សហេតុកកាមាវចរវិបាកចិត្ត ។

# មហាកិរិយាចិត្ត ៨ ដួង

[១៧]សោមនស្សសហគតំ ញាណសម្បយុត្តំ អសង្ខារិកមេកំ, សសង្ខារិកមេកំ, សោមនស្សសហគតំ ញាណវិប្បយុត្តំ អសង្ខារិកមេកំ, សសង្ខារិកមេកំ, ឧបេក្ខាសហគតំ ញាណសម្បយុត្តំ អសង្ខារិកមេកំ, សសង្ខារិកមេកំ, ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ អសង្ខារិកមេកំ, សសង្ខារិកមេកន្តិ ឥមានិ អដ្ឋបិ សហេតុកកាមាវចរកិរិយចិត្តានិ  នាម។

១.មហាកិរិយាចិត្ត កើតរួមជាមួយនឹង សោមនស្សវេទនា ប្រកបដោយបញ្ញា មិនមានអ្នកដទៃបបួលដឹកនាំ ។

២.មហាកិរិយាចិត្ត កើតរួមជាមួយនឹង សោមនស្សវេទនា ប្រកបដោយបញ្ញា មានអ្នកដទៃបបួលដឹកនាំ ។

៣.មហាកិរិយាចិត្ត កើតរួមជាមួយនឹង សោមនស្សវេទនា ប្រាសចាកបញ្ញា មិនមានអ្នកដទៃបបួលដឹកនាំ ។

៤.មហាកិរិយាចិត្ត កើតរួមជាមួយនឹង សោមនស្សវេទនា ប្រាសចាកបញ្ញា មានអ្នកដទៃបបួលដឹកនាំ ។

៥.មហាកិរិយាចិត្ត កើតរួមជាមួយនឹង ឧបេក្ខាវេទនា ប្រកបដោយបញ្ញា មិនមានអ្នកដទៃបបួលដឹកនាំ ។

៦.មហាកិរិយាចិត្ត កើតរួមជាមួយនឹង ឧបេក្ខាវេទនា ប្រកបដោយបញ្ញា មានអ្នកដទៃបបួលដឹកនាំ .។

៧.មហាកិរិយាចិត្ត កើតរួមជាមួយនឹង ឧបេក្ខាវេទនា ប្រាសចាកបញ្ញា មិនមានអ្នកដទៃបបួលដឹកនាំ ។

៨.មហាកិរិយាចិត្ត កើតរួមជាមួយនឹង ឧបេក្ខាវេទនា ប្រាសចាកបញ្ញា មានអ្នកដទៃបបួលដឹកនាំ ។

ចិត្តទាំង ៨ដួងនេះ ឈ្មោះថា សហេតុកកាមាវចរកិរិយាចិត្ត ។

**និគមន៍**

[១៨]ឥច្ចេវំ សព្វថាបិ ចតុវីសតិ សហេតុកកាមាវចរកុសលវិបាក-កិរិយចិត្តានិ សមត្តានិ ។

ចប់សហេតុកកាមាវចរកុសលចិត្ត ៨ ដួង, សហេតុកកាមាវចរវិបាកចិត្ត ៨ ដួង, សហេតុកកាមាវចរកិរិយាចិត្ត ៨ ដួង (រួមត្រូវជា សហេតុកចិត្ត ២៤) ដោយប្រការទាំងពួង យ៉ាដងនេះឯង ។

**សង្គហគាថា**

[១៩]វេទនា ញាណ សង្ខារ- ភេទេន ចតុវីសតិ;
សហេតុកាមាវចរ- បុញ្ញបាកក្រិយា មតា ។

កាមាវចរកុសលចិត្ត ៨ដួង, កាមាវចរវិបាកចិត្ត ៨ ដួង, កាមាវចរកិរិយាចិត្ត ៨ ដួង ដែលមានហេតុ មាន ២៤ ដួង តាមប្រភេទនៃវេទនា បញ្ញា និងសង្ខារ ។

**គាថាសរុប**

[២០]កាមេ តេវីស ចាកានិ បុញ្ញាបុញ្ញានិ វីសតិ

ឯកាទស ក្រិយា ចេតិ ចតុបញ្ញាស សព្វថា ។

ក្នុងកាមាវចរភូមិ មានចិត្ត ៥៤ ដួង ដោយប្រការទាំងពួង គឺ វិបាកចិត្ត ២៣ ដួង, កុសលចិត្ត និង អកុសលចិត្ត ២០ ដួង និង កិរិយាចិត្ត ១១ ដួង ។

**រូបាវចរចិត្ត ១៥ ដួង**

**កុសលចិត្ត ៥ ដួង**

[២១]វិតក្កវិចារបីតិសុខេកគ្គតាសហិតំ បឋមជ្ឈានកុសលចិត្តំ; វិចារបីតិសុខេកគ្គតាសហិតំ ទុតិយជ្ឈានកុសលចិត្តំ; បីតិសុខេកគ្គតា-សហិតំ តតិយជ្ឈានកុសលចិត្តំ; សុខេកគ្គតាសហិតំ ចតុត្ថជ្ឈានកុ-សលចិត្តំ; ឧបេក្ខេកគ្គតាសហិតំ បញ្ចមជ្ឈានកុសលចិត្តញ្ចេតិ ឥមានិ បញ្ចបិ រូបាវចរកុសលចិត្តានិ នាម ។

១.បឋមជ្ឈានកុសលចិត្ត ប្រកបដោយ វិតក្ក, វិចារ, បីតិ, សុខ និង ឯកគ្គតា ។

២.ទុតិយជ្ឈានកុសលចិត្ត ប្រកបដោយ វិចារ, បីតិ, សុខ និង ឯកគ្គតា ។

៣.តតិយជ្ឈានកុសលចិត្ត ប្រកបដោយ បីតិ, សុខ និង ឯកគ្គតា ។

៤.ចតុត្ថជ្ឈានកុសលចិត្ត ប្រកបដោយ សុខ និង ឯកគ្គតា ។

៥.បញ្ចមជ្ឈានកុសលចិត្ត ប្រកបដោយ ឧបេក្ខា និង ឯកគ្គតា ។

ចិត្តទាំង ៥ ដួងនេះ ឈ្មោះថា រូបាវចរកុសលចិត្ត ។

## វិបាកចិត្ត ៥ ដួង

[២២]វិតក្កវិចារបីតិសុខេកគ្គតាសហិតំ បឋមជ្ឈានវិបាកចិត្តំ, វិចារបីតិសុខេកគ្គតាសហិតំ ទុតិយជ្ឈានវិបាកចិត្តំ, បីតិសុខេកគ្គតា-សហិតំ តតិយជ្ឈានវិបាកចិត្តំ, សុខេកគ្គតាសហិតំ ចតុត្ថជ្ឈានវិបាកចិត្តំ, ឧបេក្ខេកគ្គតាសហិតំ បញ្ចមជ្ឈានវិបាកចិត្តញ្ចេតិ ឥមានិ បញ្ចបិ រូបាវចរវិបាកចិត្តានិ នាម ។

១.បឋមជ្ឈានវិបាកចិត្ត ប្រកបដោយ វិតក្ក, វិចារ, បីតិ, សុខ និង ឯកគ្គតា ។

២.ទុតិយជ្ឈានវិបាកចិត្ត ប្រកបដោយ វិចារ, បីតិ, សុខ និង ឯកគ្គតា ។

៣.តតិយជ្ឈានវិបាកចិត្ត ប្រកបដោយ បីតិ, សុខ និង ឯកគ្គតា ។

៤.ចតុត្ថជ្ឈានវិបាកចិត្ត ប្រកបដោយ សុខ និង ឯកគ្គតា ។

៥.បញ្ចមជ្ឈានវិបាកចិត្ត ប្រកបដោយ ឧបេក្ខា និង ឯកគ្គតា ។

ចិត្តទាំង ៥ ដួងនេះ ឈ្មោះថា រូបាវចរវិបាកចិត្ត ។

## កិរិយាចិត្ត ៥ ដួង

[២៣]វិតក្កវិចារបីតិសុខេកគ្គតាសហិតំ បញ្ចមជ្ឈានកិរិយចិត្តំ, វិចារបីតិសុខេកគ្គតាសហិតំ ទុតិយជ្ឈានកិរិយចិត្តំ, បីតិសុខេកគ្គតា-សហិតំ តតិយជ្ឈានកិរិយចិត្តំ, សុខេកគ្គតាសហិតំ ចតុត្ថជ្ឈានកិរិយចិត្តំ,

ឧបេក្ខេកគ្គតាសហិតំ បញ្ចមជ្ឈានកិរិយចិត្តញ្ចេតិ ឥមានិ បញ្ចបិ រូបាវចរ-កិរិយចិត្តានិ នាម ។

១.បឋមជ្ឈានកិរិយាចិត្ត ប្រកបដោយ វិតក្ក, វិចារ, បីតិ, សុខ និង ឯកគ្គតា ។

២.ទុតិយជ្ឈានកិរិយាចិត្ត ប្រកបដោយ វិចារ, បីតិ, សុខ និង ឯកគ្គតា ។

៣.តតិយជ្ឈានកិរិយាចិត្ត ប្រកបដោយ បីតិ, សុខ និង ឯកគ្គតា ។

៤.ចតុត្ថជ្ឈានកិរិយាចិត្ត ប្រកបដោយ សុខ និង ឯកគ្គតា ។

៥.បញ្ចមជ្ឈានកិរិយាចិត្ត ប្រកបដោយ ឧបេក្ខា និង ឯកគ្គតា ។

ចិត្តទាំង ៥ ដួងនេះ ឈ្មោះថា រូបាវចរកិរិយាចិត្ត ។

**និគមន៍**

[២៤]ឥច្ចេវំ សព្វថាបិ បណ្ណរស រូបាវចរកុសលវិបាកកិរិយចិត្តានិ សមត្តានិ ។

ចប់រូបាវចរកុសលចិត្ត ៥ ដួង, រូបាវចរវិបាកចិត្ត ៥ ដួង, រូបាវចរកិរិយាចិត្ត ៥ ដួង, (រួមត្រូវជា) ១៥ ដួង ដោយប្រការទាំងពួង យ៉ាងនេះឯង ។

**សង្គហគាថា**

[២៥]បញ្ចធា ឈានភេទេន រូបាវចរមានសំ
បុញ្ញបាកក្រិយាភេទា តំ បញ្ចទសធា ភវេ ។

រូបាវចរចិត្តមាន ៥ដួង ដោយប្រភេទនៃឈាន, រូបាវចរចិត្តនោះ មាន ១៥

ដួង ដោយប្រភេទនៃ កុសល វិបាក កិរិយា ។

## អរូបាវចរចិត្តំ (អរូបាវចរចិត្ត ១២)

## កុសលចិត្ត ៤ ដួង

[២៦]អាកាសានញ្ចាយតនកុសលចិត្តំ, វិញ្ញាណញ្ចាយតនកុសល-ចិត្តំ, អាកិញ្ចញ្ញាតនកុសលចិត្តំ, នេវសញ្ញានាសញ្ញាយតនកុសល-ចិត្តញ្ចេតិ ឥមានិ ចត្តារិបិ អរូបាវចរកុសលចិត្តានិ នាម ។

១.អាកាសានញ្ចាយតនកុសលចិត្ត ។

២.វិញ្ញាណញ្ចាយតនកុសលចិត្ត ។

៣.អាកិញ្ចញ្ញាយតនកុសលចិត្ត ។

៤.នេវសញ្ញានាសញ្ញាយតនកុសលចិត្ត ។

ចិត្តទាំង ៤ ដួងនេះ ឈ្មោះថា អរូបាវចរកុសលចិត្ត ។

## អរូបាវចរវិបាកចិត្ត ៥ ដួង

[២៧]អាកាសានញ្ចាយតនវិបាកចិត្តំ, វិញ្ញាណញ្ចាយតនវិបាកចិត្តំ, អាកិញ្ចញ្ញាយតនវិបាកចិត្តំ, នេវសញ្ញានាសញ្ញាយតនវិបាកចិត្តញ្ចេតិ ឥមានិ ចត្តារិបិ អរូបាវចរកុសលចិត្តានិ នាម ។

១.អាកាសានញ្ចាយតនវិបាកចិត្ត ។

២.វិញ្ញាណញ្ចាយតនវិបាកចិត្ត ។

៣.អាកិញ្ចញ្ញាយតនវិបាកចិត្ត ។

៤.នេវសញ្ញានាសញ្ញាយតនវិបាកចិត្ត ។

ចិត្តទាំង ៤ ដួងនេះ ឈ្មោះថា អរូបាវចរវិបាកចិត្ត ។

## អរូបាវចរកិរិយាចិត្ត ៥ ដួង

[២៨]អាកាសានញ្ចាយតនកិរិយចិត្តំ, វិញ្ញាណញ្ចាយតនកិរិយចិត្តំ, អាកិញ្ចញ្ញាយតនកិរិយចិត្តំ, នេវសញ្ញានាសញ្ញាយតនកិរិយចិត្តញ្ចេតិ ឥមានិ ចត្តារិបិ អរូបាវចរវិបាកចិត្តានិ នាម ។

១.អាកាសានញ្ចាយតនកិរិយាចិត្ត ។

២.វិញ្ញាណញ្ចាយតនកិរិយាចិត្ត ។

៣.អាកិញ្ចញ្ញាយតនកិរិយាចិត្ត ។

៤.នេវសញ្ញានាសញ្ញាយតនកិរិយាចិត្ត ។

ចិត្តទាំង ២ ដួងនេះ ឈ្មោះថា អរូបាវចរវិបាកចិត្ត ។

## និគមន៍

[២៩]ឥច្ចេវំ សព្វថាបិ ទ្វាទស អរូបាវចរកុសលវិបាកកិរិយ-ចិត្តានិ សមត្តានិ ។

អរូបាវចរកុសលវិបាកកិរិយចិត្ត ១២ ដួង សូម្បីដោយប្រការទាំងពួង ចប់-ដោយបរិបូណ៌ ។

## សង្គហគាថា

[៣០]អាលម្ពណប្បភេទេន ចតុធារុប្បមានសំ
បុញ្ញបាកក្រិយាភេទា បុន ទ្វាទសធា ឋិតំ ។

អរូបាវចរចិត្តមាន ៤ ដួង ដោយប្រភេទនៃអារម្មណ៍, មាន ១២ ដួង ដោយប្រភេទនៃកុសល វិបាក កិរិយា ។

## លោកុត្តរចិត្តដោយសង្ខេប ៨ដួង

## មគ្គចិត្ត ៤ដួង

[៣១]សោតាបត្តិផលចិត្តំ, សកទាគាមិមគ្គចិត្តំ, អនាគាមិមគ្គចិត្តំ, អរហត្តមគ្គចិត្តញ្ចេតិ ឥមានិ ចត្តារិបិ លោកុត្តរកុសលចិត្តានិ នាម ។

១.ចិត្តដែលប្រកបដោយសោតាបត្តិមគ្គ ។

២.ចិត្តដែលប្រកបដោយសកទាគាមិមគ្គ ។

៣.ចិត្តដែលប្រកបដោយអនាគាមិមគ្គ ។

៤.ចិត្តដែលប្រកបដោយអរហត្តមគ្គ ។

ចិត្តទាំង ៤ នេះ ឈ្មោះថា លោកុត្តរកុសលចិត្ត ។

## ផលចិត្ត ៤ ដួង

[៣២] សោតាបត្តិផលចិត្តំ, សកទាគាមិផលចិត្តំ, អនាគាមិ-

មគ្គចិត្តំ, អរហត្តផលចិត្តញ្ចេតិ ឥមានិ ចត្តារិបិ លោកុត្តរវិបាកចិត្តានិ នាម ។

១.ចិត្តដែលប្រកបដោយសោតាបត្តិផល ។

២.ចិត្តដែលប្រកបដោយសកទាគាមិផល ។

៣.ចិត្តដែលប្រកបដោយអនាគាមិផល ។

៤.ចិត្តដែលប្រកបដោយអរហត្តផល ។

ចិត្តទាំង ៤ នេះ ឈ្មោះថា លោកុត្តរវិបាកចិត្ត ។

**និគមន៍**

[៣៣]ឥច្ចេវំ សព្វថាបិ អដ្ឋ លោកុត្តរកុសលវិបាកចិត្តានិ សមត្តានិ ។

ចប់លោកុត្តរកុសល ៤ ដួង, លោកុត្តរវិបាកចិត្ត ៤ ដួង ទាំំង រួមជា ៨ ដួង ដោយប្រការយ៉ាងនេះ។

**សង្គហគាថា**

[៣៤]ចតុមគ្គប្បភេទេន ចតុធា កុសលំ តថា

បាកំ តស្ស ផលត្តាតិ អដ្ឋធានុត្តរំ មតំ ។

លោកុត្តរចិត្តមាន ៨ ដួងគឺ លោកុត្តរកុសលចិត្តមាន ៤ ដួង តាមប្រភេទនៃមគ្គ ៤ និងលោកុត្តរវិបាកចិត្តាមាន ៤ ដួង ដូចគ្នា ព្រោះជាផលរបស់លោកុត្តរកុសលចិត្ត នោះឯង ។

## ចិត្តដោយសង្ខេប ៨៩ ដួង

## សង្គហគាថាសម្តែងចិត្តដោយជាតិ

[៣៥]ទ្វាទសាកុសលានេវំ កុសលានេកវីសតិ
ឆត្តឹសេវ វិបាកានិ ក្រិយចិត្តានិ វីសតិ ។

អកុសលចិត្ត ១២ ដួង, កុសលចិត្ត ២១ ដួង, វិបាកចិត្ត ៣៦ ដួង, និង កិរិយាចិត្ត ២០ ដួង យ៉ាងនេះ ។

## សង្គហគាថាសម្តែងចិត្តដោយភូមិ

[៣៦]ចតុប្បញ្ញាសធា កាមេ រូបេ បណ្ណរសីរយេ
ចិត្តានិ ទ្វាទសារុប្បេ អដ្ឋធានុត្តរេ តថា ។

ព្រះមានព្រះភាគត្រាស់សម្តែងចិត្តក្នុងកាមភូមិមាន ៥៤ ដួង, ក្នុងរូបភូមិមាន ១៥ ដួង, ក្នុងអរូបភូមិ ១២ ដួង, និងលោកុត្តរភូមិមាន ៨ ដួង ។

### និគមន៍

[៣៧] ឥត្ថមេកូនវុតិ បភេទំ បន មានសំ
ឯកវីសសតំ វាថ វិភជន្តិ វិចក្ខណា ។

ន័យម្យ៉ាងទៀត អ្នកប្រាជ្ញ បានបែងចែក នូវចិត្តជា ៨៩ ដួង ដូចពោលមក នេះ ជា ១២១ ដួង ។

## ចិត្តដោយពិស្តារ ១២១ ដួង

## [៣៨] កាចមេកូនវុត្តិវិធំ ចិត្តំ ឯកវីសសតំ ហោតិ ?

ចិត្តមាន ៨៩ ដួង ជាចិត្ត ១២១ ដួង តើដូចម្ដេច ?

## **លោកុត្តរចិត្តពិស្ដារ ៤០ ដួង**

## **សោតាបត្តិមគ្គចិត្ត ៥ ដួង**

វិតក្កវិចារបីតិសុខេកគ្គតាសហិតំ បឋមជ្ឈានសោតាបត្តិមគ្គចិត្តំ, វិចារបីតិសុខេកគ្គតាសហិតំ ទុតិយជ្ឈានសោតាបត្តិមគ្គចិត្តំ, បីតិសុខេ-កគ្គតាសហិតំ តតិយជ្ឈានសោតា បត្តិមគ្គចិត្តំ, សុខេកគ្គតាសហិតំ ចតុត្ថជ្ឈានសោតាបត្តិមគ្គចិត្តំ, ឧបេក្ខេកគ្គតាសហិតំ បញ្ចមជ្ឈានសោ-តាបត្តិមគ្គចិត្តញ្ចេតិ ឥមានិ បញ្ចបិ សោតាបត្តិមគ្គចិត្តានិ ជាម ។

១.សោតាបត្តិមគ្គចិត្ត ដែលប្រកបដោយបឋមជ្ឈាន កើតរួមជាមួយនឹង វិតក្ក វិចារ បីតិ សុខ និងឯកគ្គតា ។

២.សោតាបត្តិមគ្គចិត្ត ដែលប្រកបដោយទុតិយជ្ឈាន កើតរួមជាមួយនឹង វិចារ បីតិ សុខ និងឯកគ្គតា ។

៣.សោតាបត្តិមគ្គចិត្ត ដែលប្រកបដោយតតិយជ្ឈាន កើតរួមជាមួយនឹង បីតិ សុខ និង ឯកគ្គតា ។

៤.សោតាបត្តិមគ្គចិត្ត ដែលប្រកបដោយចតុត្ថជ្ឈាន កើតរួមជាមួយនឹង សុខ និង ឯកគ្គតា ។

៥.សោតាបត្តិមគ្គចិត្ត ដែលប្រកបដោយបញ្ចមជ្ឈាន កើតរួមជាមួយនឹង ឧបេក្ខា និង ឯកគ្គតា ។

ចិត្តទាំង ៥ ដួង នេះ ឈ្មោះថា សោតាបត្តិមគ្គចិត្ត ។

## មគ្គចិត្តខាងលើ ២០ ដួង និង ផលចិត្ត ២០ ដួង

[៣៩]តថា សកទាគាមិមគ្គ អនាគាមិមគ្គ អរហត្តមគ្គចិត្តញ្ចេតិ សមវីសតិ មគ្គចិត្តានិ ។

ដូចគ្នានេះដែរ សកទាគាមិមគ្គចិត្ត អនាគាមិមគ្គចិត្ត អរហត្តមគ្គចិត្ត ក៏ដូចគ្នា (ក្នុងចិត្តមួយៗមានចិត្ត ៥ ដួង ដូចគ្នា) ព្រោះដូច្នោះ ទើបរួមជាមគ្គចិត្ត ២០ ដួង ។

[៤០]តថា ផលចិត្តានិ ចេតិ សមចត្តាឡីស លោកុត្តរចិត្តានិ ភវន្តីតិ ។

ផលចិត្ត ក៏ដូចគ្នា (មាន ២០ ដួង ដូចមគ្គចិត្ត) ដូច្នោះ ទើបរួមជាលោកុត្តរចិត្ត ៤០ ដួង ។

## សង្គហគាថា

[៤១]ឈានង្គយោគភេទេន កត្វេកេកំ តុ បញ្ចធា
វុច្ចតានុត្តរំ ចិត្តំ ចត្តាឡីស វិធន្តិ ច ។

ក៏ចំណែកឯលោកុត្តរចិត្តលោកពោលថា មាន ៤០ ដួង ដោយចំណែកមួយៗ មាន ៥ តាមប្រភេទនៃអង្គឈាន ។

## សង្គហគាថាសម្តែងលោកិយ និង លោកុត្តរឈានចិត្តរួមគ្នា

[៤២]យថា ច រូបាវចរំ　　គយ្ហតានុត្តរំ តថា

បឋមាទិឈានភេទេ　　អារុប្បញ្ចាបិ បញ្ចមេ ។

ឯកាទសវិធំ តស្មា　　បឋមាទិកមីរិតំ

ឈានមេកេកមន្តេ តុ　　តេវីសតិវិធំ ភវេ ។

លោកសម្តែងលោកុត្តរចិត្តតាមប្រភេទនៃឈាន មានបឋមជ្ឈានជាដើម ដូចរូបាវចរចិត្ត និងអរូបាវចរចិត្ត លោកសម្តែងទុកក្នុងបញ្ចមជ្ឈាន ព្រោះដូច្នោះ ឈានចិត្តដែលប្រកបដោយបឋមជ្ឈាន ជាដើម ឈានមួយមាន ១១ ដួង ប៉ុន្តែក្នុងឈានចិត្តខាងចុងមាន ២៣ ដួង ។

## សង្គហគាថាសម្តែងកុសល និង វិបាកពិស្តារ

[៤៣]សត្តតឹស វិធំ បុញ្ញំ　　ទ្វិបញ្ញាស វិធំ តថា

បាកមិច្ចាហុ ចិត្តានិ　　ឯកវីសសតំ ពុធា ។

កុសលចិត្តមាន ៣៧ ដួង ចំណែកវិបាកចិត្តមាន ៥២ ដួង ដូច្នោះ អ្នកប្រាជ្ញទាំងឡាយ ទើបពោលថា ចិត្តមាន ៨៩ ដួង ថាជាចិត្ត មាន ១២១ ដួង។

ឥតិ អភិធម្មត្ថសង្គហេ ចិត្តសង្គហវិភាគោ នាម បឋមោ បរិច្ឆេទោ ។

ចប់បរិច្ឆេទទី១ ឈ្មោះ ចិត្តសង្គហវិភាគ ក្នុងអភិធម្មត្ថសង្គហ ដូច្នេះឯង។